**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៧. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

**ការកាត់ដីទំហំសរុប ១១.៥០០,៥០ ហិកតា នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលក្នុងនោះ កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃរនាមដូនសំ ពីព្រៃសម្បទានយូរីសាគរ និង ពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋ ២.៧០៧ គ្រួសារ និង រក្សាទុកមួយចំណែកជាដីភ្នំ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៣/០៤៣ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៦៧៤ ខបប ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.**

- ត្រូវបានកាត់ដីទំហំសរុប ១១.៥០០,៥០ ហិកតា ដែលក្នុងនោះ (១) ទំហំ ៤.៣៩៧ ហិកតា កាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ (២) ទំហំ ១៦៣២,៥០ ហិកតា ពីព្រៃរនាមដូនសំ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០១១៣ /០៤៣ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ (៣) ទំហំ ១១៥ ហិកតា ពីព្រៃសម្បទានយូរីសាគរ និង (៤) ទំហំ ៥.៣៥៦ ហិកតា ពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ ១១.៤១៩ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៨១,៥០ ហិកតា រក្សាទុកជាដីរដ្ឋ(ភ្នំ) នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានទំហំ និងចំនួនគ្រួសារ ស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

**១.១. ឃុំព្រះផុស ស្រុកគាស់ក្រឡ**

- ផ្ទៃដីទំហំសរុប ១.៩៦២ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦០ គ្រួសារ នៅភូមិព្រៃចក
- ផ្ទៃដីទំហំសរុប ២.៥៥០ ហិកតា ដែលក្នុងនោះ ទំហំ ១១៥ ហិកតា កាត់ចេញពីព្រៃសម្បទានយូរីសាគរ និង ទំហំ ២.៤៣៥ ហិកតា ពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ២.៤៦៨,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧៧ គ្រួសារ និងទំហំ ៨១,៥០ ហិកតា រក្សាទុកជាដីរដ្ឋ(ភ្នំ) នៅភូមិតានួត

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ(១) នៃអនុក្រឹត្យនេះ។

**១.២. ឃុំស្ដៅ ស្រុកបាណន់**

- ផ្ទៃដីទំហំសរុប ២.៩១២ ហិកតា កាត់ចេញពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៣៥គ្រួសារ នៅភូមិបឹងក្រសាល
- ផ្ទៃដីទំហំសរុប ២.៩៤៩ ហិកតា កាត់ចេញពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦២២គ្រួសារ នៅភូមិបឹងប្រី

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

**១.៣. ឃុំបារាំងធ្លាក់ និងឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក**

- ផ្ទៃដីទំហំសរុប ៩១៩,៥០ ហិកតា កាត់ចេញពីព្រៃរនាមដូនសំ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៥៥ គ្រួសារ នៅភូមិអូរជ្រៃ ឃុំបារាំងធ្លាក់
- ផ្ទៃដីទំហំសរុប ៧១៨ ហិកតា កាត់ចេញពីព្រៃរនាមដូនសំ ហើយធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥៨ គ្រួសារ នៅភូមិអូរធំ ឃុំភ្នំព្រឹក

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (៣) នៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២.៧០៧ គ្រួសារ នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានទំហំ និងចំនួនគ្រួសារស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

**២.១. ឃុំព្រះផុស ស្រុកគាស់ក្រឡ**

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៦០ គ្រួសារ នៅភូមិព្រៃចក
- ប្រទានកម្មទំហំ ២៩៦៨,៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៧៧ គ្រួសារ នៅភូមិតានួត

**២.២. ឃុំស្ដៅ ស្រុកបាណន់**

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៧៣៥ គ្រួសារ នៅភូមិបឹងក្រសាល
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៦២២ គ្រួសារ នៅភូមិបឹងប្រី

**២.៣. ឃុំបារាំងធ្លាក់ និងឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក**

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៥៥ គ្រួសារ នៅភូមិអូរជ្រៃ ឃុំបារាំងធ្លាក់
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥៨ គ្រួសារ នៅភូមិអូរធំ ឃុំភ្នំព្រឹក

**មាត្រា ៣.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធ(១)នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ ការកាត់ដីដំណាំសរុប ១១.៥០០,៥០ ហិកតា នៅស្រុកគាស់ក្រឡ ស្រុកបាណន់ និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលក្នុងនោះ កាត់ចេញពីតំបន់គ្រប់គ្រងព្រៃឈើអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃនាមជួនសំពីព្រៃសម្បទានយូរីសាគរ និង ពីព្រៃសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន តាពីម៉ិច ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋ ២.៧០៧ គ្រួសារ និង អនុវត្តគម្រោងចំណែកជាដីជាដីភ្លឺ




| ចំនុចនិយាមការ | | |
|---|---|---|
| ល.រ | X | Y |
| 1 | 316470 | 1403775 |
| 2 | 315854 | 1400802 |
| 3 | 315156 | 1400502 |
| 4 | 314972 | 1400086 |
| 5 | 314170 | 1400324 |
| 6 | 313674 | 1399951 |
| 7 | 313637 | 1399265 |
| 8 | 312615 | 1399143 |
| 9 | 312750 | 1393234 |
| 10 | 310557 | 1393332 |
| 11 | 310472 | 1393038 |
| 12 | 309045 | 1393363 |
| 13 | 309278 | 1393785 |
| 14 | 307802 | 1394097 |
| 15 | 307925 | 1394906 |
| 16 | 309676 | 1394557 |
| 17 | 309654 | 1401049 |
| 18 | 310746 | 1401144 |
| 19 | 310868 | 1402553 |
| 20 | 311401 | 1402699 |
| 21 | 311175 | 1403422 |
| 22 | 311793 | 1403551 |
| 23 | 311811 | 1403955 |
| 24 | 312816 | 1403808 |
| 25 | 313471 | 1403906 |
| 26 | 313526 | 1404610 |
| 27 | 312883 | 1404549 |
| 28 | 312858 | 1404861 |
| 29 | 313489 | 1404959 |
| 30 | 313471 | 1405418 |
| 31 | 314077 | 1405504 |
| 32 | 315240 | 1403893 |



**ប្រព័ន្ធកូអរដោនេ :**
តំបន់ទី : 48N
ចំណោលផែនទី : UTM
ទិន្នន័យយោង : WGS1984

**ប្រភពទិន្នន័យ:**
ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ
គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២

**គម្របព្រៃឈើ**
ព្រៃស្រោង
ព្រៃស្រោង
ព្រៃល្បោះ
ព្រៃពាក់កណ្ដាលស្រោង
ដីមិនមែនព្រៃ
ព្រំប្រទល់ដីស្នើសុំ
ព្រំប្រទល់ដីភ្លឺ
(ផ្ទៃដីភ្លឺសរុបចំនួន៨១.៥ហិកតា)